**ចម្លើយតបរបស់បណ្ឌិត Helen Jarvis ចំពោះការអំពាវនាវឲ្យមានការចូលរួមគំនិត អំពីមុខងារនៅសេសសល់របស់ អ.វ.ត.ក ទាក់ទងនឹងជនរងគ្រោះ**

មុនពេលបង្ហាញនូវគំនិតរបស់ខ្ញុំ ខ្ញុំសូមសម្តែងការកោតសរសើរចំពោះចៅក្រម យូរ ឧត្តរា និងចៅក្រម Fenz ដែលបានចេញសេចក្តីអំពាវនាវនេះ ដែលសង្ឃឹមថាជាការបើកផ្លូវឲ្យមានការពិភាក្សាពេញលេញ និងដោយតម្លាភាពទៅលើបញ្ហានេះ ដែលជាក្តីបារម្ភចម្បងរបស់ដើមបណ្តឹងរដ្ឋប្បវេណី របស់ជនរងគ្រោះទាំងអស់នៃរបបខ្មែរក្រហម និងរបស់ប្រជាជនកម្ពុជាទាំងមូល ព្រមទាំងអ្នកទាំងឡាយនៅក្នុងសហគមន៍អន្តរជាតិ ដែលចូលរួមពាក់ព័ន្ធក្នុងការស្វែងរកយុត្តិធម៌។

ចំពោះខ្ញុំវាហាក់ដូចជាថា មុខងារសេសសល់ទាក់ទងជនរងគ្រោះ ដូចខាងក្រោមនេះ ត្រូវបានកំណត់នៅក្នុងរបាយការណ៍របស់អគ្គលេខាធិការ ដែលមានចំណងជើងថា *អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មុខងារនៅសេសសល់* (A/75/809) ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០២១ និងសំណើកិច្ចព្រមព្រៀងបន្ថែម ទៅលើកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក។

**១. បណ្ណសារ និងព័ត៌មាន**

. រក្សា អភិរក្ស និងគ្រប់គ្រងបណ្ណសាររបស់ខ្លួន រួមទាំងការចាត់ចំណាត់ថ្នាក់ឡើងវិញ

. ឆ្លើយតបចំពោះសំណើសុំចូលពិនិត្យមើលឯកសារ

. ផ្សព្វផ្សាយព័ត៌មានទៅសាធារណជនអំពី អ.វ.ត.ក

តាមគំនិតរបស់ខ្ញុំ មុខងារទាំងអស់នេះ អាច និងគួរតែប្រគល់ទៅឲ្យមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ ដោយយោងតាមការពិតដែលថា រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតស្ថាប័ននេះឡើង តាមអនុក្រិត្យលេខា ១៥៩អនក្រ-បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៥ ដោយមានការគាំទ្រហិរញ្ញវត្ថុយ៉ាងប្រសើរពីប្រទេសជប៉ុន ដែលស្ថាប័ននេះមានភារកិច្ច បំពេញមុខងារបែបនេះ ពាក់ព័ន្ធទៅនឹង អ.វ.ត.ក។

បន្ថែមលើនេះ គួររំឭកផងដែរថា ស្ថាប័ននេះត្រូវបានអនុម័តយល់ព្រម ដោយសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក ក្នុងសំណុំរឿង ០០២/០២ ដែលបានប្រកាសកាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ជាគម្រោងសំណងមួយ ដែលស្នើឡើងដោយសហមេធាវីនាំមុខ តំណាងដើមបណ្តឹងរដ្ឋប្បវេណី *ការទទួលបាន*

*កំណត់ត្រាតុលាការ នៃសាលាក្ដីខ្មែរក្រហម និងសម្ភារៈដើមបណ្ដឹងរដ្ឋប្បវេណី នៅមជ្ឈមណ្ឌលតម្កល់ឯកសារកម្ពុជា ទាក់ទងនឹង អ.វ.ត.ក។*

ឯកសារទាំងអស់ដែលត្រូវបានចាត់ចំណាត់ថ្នាក់ជាសាធារណៈ ទាក់ទងសំណុំរឿង ០០១ និងសំណុំរឿង ០០២/០១ ត្រូវបានបញ្ជូនរួចរាល់ហើយ ហើយឯកសារសាធារណៈដែលនៅសល់ ត្រូវបានរំពឹងថានឹងត្រូវបញ្ជូននាពេលអនាគត តាមការណែនាំរបស់មន្ត្រីតុលាការ បន្ទាប់ពីមានការត្រួតពិនិត្យដោយតុលាការ ទៅលើកម្រិតចំណាត់ថ្នាក់បច្ចុប្បន្ននៃឯកសារ ដែលមាននៅក្នុងសំណុំរឿង។ មានការរំពឹងទុកថា ឯកសារក្នុងចំនួនយ៉ាងច្រើននឹងត្រូវចាត់ចំណាត់ថ្នាក់ឡើងវិញជាសាធារណៈ នៅពេលដែលកិច្ចដំណើរការនីតិវិធីជំនុំជម្រះ នៅក្នុងសំណុំរឿងដទៃទៀត ត្រូវបានបិទបញ្ចប់ (ដូចគ្នានឹងក្នុងសំណុំរឿង ០០១)។ មានការលើកឡើងថា ការត្រួតពិនិត្យនេះអាចពិចារណាផងដែរ លើការផ្ដល់អនុសាសន៍ ឱ្យប្រគល់ឯកសារច្បាប់ដើម ទៅម្ចាស់របស់គេ ទៅស្ថាប័នដែលផលិតឯកសារនោះ ឬអ្នកបន្តវេន (ដូចជាឯកសារពីស-២១ ត្រូវប្រគល់ទៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង) ដោយឯកសារចម្លងត្រូវរក្សាទុក នៅក្នុងបណ្ណាសារ អ.វ.ត.ក។

កិច្ចពិភាក្សាលើការសម្រេចចំពោះ ឯកសារដែលនៅតែត្រូវចាត់ចំណាត់ថ្នាក់ សម្ងាត់ឬសម្ងាត់បំផុត ចាំបាច់ត្រូវតែធ្វើឡើង ជាផ្នែកនៃដំណើរការបញ្ចប់ ដោយយោងទៅតាមច្បាប់ និងនីតិវិធីដែលនៅជាធរមានរបស់កម្ពុជា។ ការបញ្ជូននេះ ក៏រួមបញ្ចូលផ្នែកភស្តុភារផងដែរ នូវកំណត់ត្រា និងឯកសាររដ្ឋបាល ពីផ្នែកដទៃទៀត នៃការិយាល័យរដ្ឋបាល រួមទាំងផ្នែកកិច្ចការសាធារណៈ អង្គភាពគាំពារជនរងគ្រោះ និងបណ្ណាល័យផងដែរ។

ដើម្បីត្រៀមរៀបចំការផ្ទេរបែបនេះ ជាការស្នើឡើងគឺថាបុគ្គលិកនៅមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ គួរបញ្ជូនទៅ អ.វ.ត.ក ដើម្បីធ្វើការងារដោយជិតស្និទ្ធិជាមួយផ្នែកបណ្ណាសារ ដើម្បីឱ្យពួកគេអាចយល់ដឹងបានប្រសើរអំពីរចនាសម្ព័ន្ធនៃសំណុំរឿង និងនីតិវិធីបន្ទាប់ពីការចាត់ចំណាត់ថ្នាក់ឡើងវិញ។ ជាការល្អ ការបញ្ជូនទៅបែបនេះគួររៀបចំធ្វើឡើង ឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន។ បន្ថែមលើនេះ ការពិភាក្សាគួរចាប់ផ្ដើមភ្លាមៗ ទាក់ទងនឹងកម្មវិធីដែលត្រូវប្រើប្រាស់ សម្រាប់គ្រប់គ្រងសំណុំរឿង ជាពិសេសថាតើកម្មវិធី Zylab បច្ចុប្បន្ន នឹងត្រូវផ្ដល់ជូនទៅមជ្ឈមណ្ឌលឯកសារច្បាប់ ដើម្បីការគ្រប់គ្រងបន្តរដែរឬអត់ ទៅលើបណ្ណាសារទាំងអស់នេះ និងប្រសិនបើផ្ដល់ជូន តើត្រូវផ្ដល់ជូនក្រោមលក្ខណៈអ្វី និងមានការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសបែបណា សម្រាប់ប្រតិបត្តិការបន្តរ ឬត្រូវស្វែងរកកម្មវិធីជំនួសផ្សេង ដែលមានតម្លៃសមរម្យជាង។

## ២. សំណាង

ទោះបីជានៅក្នុងប្រទេសប្រកាន់ប្រព័ន្ធច្បាប់ស៊ីវិលឡ រួមទាំងប្រទេសកម្ពុជាដែរនោះ ដែលសំណាងដែលផ្តល់ជូនដោយតុលាការព្រហ្មទណ្ឌ ត្រូវអនុវត្តក្រោមការគ្រប់គ្រងរបស់តុលាការក្តី ប៉ុន្តែ អ.វ.ត.ក មានអាណត្តិការងារ ក្នុងរបៀបរបបផ្សេង ដោយសំណាងអាចត្រូវបានស្នើឡើង ដោយភាគីទីបី ហើយប្រសិនបើត្រូវបានអនុម័តជាផ្នែកនៃសាលក្រម សំណាងនោះត្រូវអនុវត្តដោយស្ម័គ្រចិត្ត ដោយភាគីដែលស្នើឡើង ដោយមានលទ្ធភាពទទួលបានការគាំទ្រពីអ្នកដទៃ។ ជាការគួរឲ្យចាប់អារម្មណ៍ ដែលត្រូវយល់ដឹងថាក្នុងកម្រិតណា និងក្នុងរយៈពេលប៉ុន្មាន ដែលតុលាការ អ.វ.ត.ក នឹងសម្រេចថាត្រូវដើរតួ ក្នុងការគ្រប់គ្រងលើការអនុវត្ត ឬវាយតម្លៃលើប្រសិទ្ធិភាពនៃសំណាងដែលត្រូវផ្តល់ជូន។

ហេតុដូច្នេះ ជាការចាំបាច់ដែលត្រូវពិភាក្សា ពីលក្ខខណ្ឌនៃមុខងារនេះ។ មានការស្នើឡើងថា គួរមានការត្រួតពិនិត្យឡើងវិញលើស្ថានភាពបច្ចុប្បន្ននៃគម្រោងសំណាងទាំងអស់ដែលត្រូវបានទទួលស្គាល់ រហូតមកដល់បច្ចុប្បន្ន។ ទោះបីជាគម្រោងជាច្រើនត្រូវបានប្រមើលមើលថា មានរយៈពេលកំណត់ក្តី ហើយតាមពិតទៅគម្រោងខ្លះ បានឈានដល់ទីបញ្ចប់ក្តី ចំពោះគម្រោងដែលនៅសល់ ដែលកំពុងតែបន្ត ការគ្រប់គ្រង និងរាយការណ៍ដែលត្រូវធ្វើ (ព្រមទាំងការស្វែងរកលទ្ធភាព និងប្រភពនៃមូលនិធិ សម្រាប់ការបន្តគម្រោងនោះ) ក៏ប្រហែលជាអាចប្រគល់ដោយសមស្របផងដែរ ទៅមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ ដោយសារតែទំនាក់ទំនងតាមការងារជាក់លាក់ ព្រមទាំងការទទួលខុសត្រូវចំពោះ ដើមបណ្តឹងរដ្ឋប្បវេណី ប្រសិនបើរចនាសម្ព័ន្ធនៃមជ្ឈមណ្ឌលនេះត្រូវបានពង្រីកបន្ថែម ដើម្បីបន្ថែមនាយកដ្ឋានសំណាង (ប្រហែលក្នុងរយៈពេលជាក់លាក់មួយ និងប្រហែលរួមជាមួយមន្ត្រី បុគ្គលិក និងមន្ត្រីច្បាប់ ដែលនៅក្នុងផ្នែកគាំពារជនរងគ្រោះ និង/ឬ ផ្នែកសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបច្ចុប្បន្ន)។

គួរកត់សម្គាល់ផងដែរថា សកម្មភាពខ្លះដែលស្ថិតក្រៅកម្មវិធីសំណាង អ.វ.ត.ក ក៏បំពេញតួនាទីក្នុងការផ្តល់សំណាងទៅដល់ជនរងគ្រោះនៃរបបខ្មែរក្រហមដែរ ឧទាហរណ៍ដូចជា គម្រោងសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ដែលអភិរក្ស និងផ្លាស់ប្តូរទៅជាឌីជីថល នូវបណ្ណាសារស-២១ ការថែទាំសុខភាពផ្លូវចិត្តដែលកំពុងដំណើរការ ជាពិសេសដោយអង្គការចិត្តសង្គម អន្តរវប្បធម៌ កម្មវិធីស្រាវជ្រាវនិងវប្បធម៌ និងកិច្ចប្រឹងប្រែងដោយឯករាជ្យ របស់សហគមន៍ ក្នុងការកសាងស្តូបរំលឹក និងចេតិយ ដែលគួរឲ្យកត់សម្គាល់។ ពិតជាមាន

តម្លៃក្នុងការផ្ដួចផ្ដើម ការចងក្រងសកម្មភាពបែបនេះ ដើម្បីបង្កើតនូវកំណត់ត្រា ដើម្បីបង្ហាញនូវរូបភាពធំទូលាយ ថាតើអត្ថិភាពរបស់ អ.វ.ត.ក បានជម្រុញ និងបណ្ដាលឲ្យមានលទ្ធផលជាវិជ្ជមានបែបនេះ ដោយរបៀបណា។

**មតិសន្និដ្ឋាន**

ខ្ញុំសូមឆ្លៀតយកឱកាសនេះ ដើម្បីលើកយោបល់ដោយទូលាយ ទាក់ទងនឹងសេចក្ដីព្រាងកិច្ចព្រមព្រៀងបន្ថែម។ មានការស្នើឡើងថា បន្ទាប់ពី អ.វ.ត.ក បានបញ្ចប់សំណុំរឿងរបស់ខ្លួនហើយ អ.វ.ត.ក ដែលមានទំហំតូចជាងមុន ត្រូវបន្តប្រតិបត្តិការ ដែលដំបូងមានរយៈពេលបីឆ្នាំ ដើម្បីអនុវត្តមុខងារនៅសេសសល់ ដោយមានគម្រោងថវិកាជិត៣លានដុល្លា ក្នុងមួយឆ្នាំ (ផ្នែកអន្តរជាតិចំនួន ១.៩៧៤.៥០០ ដុល្លា ក្នុងមួយឆ្នាំ និងផ្នែកជាតិប្រមាណ ១.០២០.៥០០ ដុល្លា ក្នុងមួយឆ្នាំ) ដោយមានបុគ្គលិក ៣៣ នាក់ (អន្តរជាតិ ១១ នាក់ និងជាតិ ២២ នាក់)។

ប្រាកដណាស់ថា ជាផ្នែកនៃយុទ្ធសាស្ត្របញ្ចប់សម្រាប់ អ.វ.ត.ក ជាការចាំបាច់ដែលត្រូវពិភាក្សា និងឈានដល់ការព្រមព្រៀង លើយន្តការសម្រាប់ការអនុវត្តមុខងារនៅសេសសល់ (មិនត្រឹមតែទាក់ទងនឹងជនរងគ្រោះ ដូចបានពិភាក្សាខាងលើប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមុខងារតុលាការជាច្រើនផ្សេងទៀត ដូចមានគូសបញ្ជាក់នៅក្នុងកិច្ចព្រមព្រៀងបន្ថែម ព្រមទាំងបញ្ហាដទៃទៀត ដែលមិនបានលើកឡើង ដូចជាការចាត់ចែងទ្រព្យសម្បត្តិ កាលវិភាគកាត់បន្ថយបុគ្គលិកជាដើម)។ ខ្ញុំមានចម្ងល់ថាតើ អាចស្វែងរកវិធីសាស្ត្រផ្សេង ដែលមិនឃ្លាតចេញពីបញ្ញត្តិដែលត្រូវផុតកំណត់ជាស្វ័យប្រវត្តិ របស់ច្បាប់ អ.វ.ត.ក (មាត្រា ៤៧) ហើយដែលត្រូវបានរៀបចំឡើងក្នុងលក្ខណៈមិនសូវស្មុគស្មាញ និងចំណាយតិចជាងការពន្យាពេល អ.វ.ត.ក ដូចបានស្នើឡើង ដែរឬទេ (បើទោះបីជាមានទម្រង់ជាការកាត់បន្ថយក្ដី) ក្នុងរយៈពេលយ៉ាងតិចបីឆ្នាំ បន្ទាប់ពីបញ្ចប់សំណុំរឿងរបស់ខ្លួននោះ។

ហត្ថលេខា

បណ្ឌិត Helen Javis រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២១